ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ :...១៧៩...ដនស./សរ

ភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០០៥

**សេចក្តីជូនដំណឹង**

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ជំរាបមក
លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង

**កម្មវត្ថុ** : ការទទួលខុសត្រូវ លើលិខិតសញ្ញាផ្ទេរសិទ្ធិ ។

កន្លងមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បានកត់សំគាល់ឃើញថា : រាល់លិខិតសញ្ញាផ្ទេរសិទ្ធិអ្នកកាន់កាប់អចលនវត្ថុ ដែលការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក-ខ័ណ្ឌ តាក់តែង និង បញ្ជូនឡើងតាមលំដាប់ថ្នាក់នោះ នៅមានភាពខ្វះចន្លោះ ក្នុងការទទួលខុសត្រូវឱ្យបានដាច់ខាត ក្នុងការតាក់តែងលិខិតសញ្ញាទាំងនោះ ។

ដើម្បីមានមូលដ្ឋានទទួលខុសត្រូវនៅពេលជួបប្រទះបាតុភាពផ្សេងៗ ដែលកើតឡើង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមជំរាបជូនថា រាល់លិខិតសញ្ញាផ្ទេរសិទ្ធិអ្នកកាន់កាប់អចលនវត្ថុ ត្រូវសរសេរឈ្មោះ និង ចុះហត្ថលេខាទទួលខុសត្រូវ ។ នៅពេលតាក់តែងលិខិតសញ្ញាចប់សព្វគ្រប់ហើយ អ្នកតែងលិខិតសញ្ញាត្រូវចុះហត្ថលេខា និង ឈ្មោះនៅរឹមខាងលើទំព័រទី១ នៃលិខិតសញ្ញាដែលបោះពុម្ព ដាក់ថា " អ្នកតែងលិខិត " ដោយប្រធាន ឬ អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក-ខ័ណ្ឌ ដែលមានជំនាញបច្ចេកទេសការងារសុរិយោដី ។ ករណីដែលថ្នាក់ដឹកនាំការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលណាពុំមានជំនាញបច្ចេកទេសការងារសុរិយោដី ត្រូវឱ្យមន្ត្រីដែលមានជំនាញបច្ចេកទេសការងារសុរិយោដី ជាអ្នកតាក់តែង និង ចុះហត្ថលេខាលើលិខិតសញ្ញា ។ លិខិតសញ្ញាត្រូវធ្វើជាពីរច្បាប់ សរសេរបំពេញដោយដៃ មិនឱ្យកោសលុប ឬ សរសេរជ្រៀត ឬ គ្រួតលើគ្នា តាមរូបមន្តឱ្យបានត្រឹមត្រូវ ។

នៅពេលឯកសារនេះមកដល់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត-ក្រុង ប្រធានការិយាល័យសុរិយោដី ត្រូវពិនិត្យបន្ថែមទៀត ។ បើពិនិត្យឃើញមានលក្ខណៈត្រឹមត្រូវ និង គ្រប់គ្រាន់ហើយ អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត-ក្រុង ទទួលបន្ទុកការងារសុរិយោដី ត្រូវចុះ ។/

អាស័យដ្ឋាន លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
MLMUPC Tel/Fax (855-23) 215 660, E-mail: mlmupc@camnet.com.kh, LMAP Tel/Fax: (855-23) 211 354, E-mail: lmap@camnet.com.kh

ហត្ថលេខាបំពេញ ចុះថ្ងៃ-ខែ-ឆ្នាំ និង បោះត្រាលេខាចារឹកនៅពីខាងមុខតួលេខតម្លៃអចលនវត្ថុ ត្រង់បន្ទាត់ "តម្លៃជាប្រាក់......" រួចចាត់ការតាមមុខសញ្ញា ៖

១- បើខេត្ត-ក្រុងណាដែលបានទទួលប្រតិភូកម្មហត្ថលេខា ពីក្រសួងរួចហើយ ត្រូវចាត់ការចុះបញ្ជី បន្ត និង បញ្ជូនតារាងផ្លាស់ប្តូរ ព្រមទាំងឯកសារលោបទាំងអស់ ទៅអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ ដើម្បីពិនិត្យ និង ចុះបញ្ជី ។

២- ចំពោះខេត្ត-ក្រុង ដែលពុំទាន់បានទទួលប្រតិភូកម្មហត្ថលេខា ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ ដើម្បីចាត់ការពិនិត្យ និង ចុះបញ្ជីបន្ត ។

ដូចបានជំរាបខាងលើនេះ ខ្ញុំសង្ឃឹមថា អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីគ្រប់ខេត្ត-ក្រុង នឹងផ្សព្វផ្សាយជាទូលាយ ដល់មន្ត្រីរាជការទាំងអស់ក្រោមឱវាទ ជាពិសេសប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលគ្រប់ស្រុក-ខណ្ឌ ឱ្យអនុវត្តប្រកបដោយប្រសិទ្ធិភាព ចាប់ពីថ្ងៃចេញលិខិតនេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

អ៊ឹម ឈុនលឹម

ចម្លងជូន ៖

- អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ
- អគ្គនាយកដ្ឋានរដ្ឋបាល

"ដើម្បីមុខការ"

- ឯកសារ កាលប្បវត្តិ